**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារ
# បុគ្គលិកនិយោជិត នៃក្រុមហ៊ុនហ្វា តើហ្វមមីង សូសល អេនធើប្រាយ

កិច្ចព្រមព្រៀងនេះធ្វើឡើងរវាង៖

ក្រុមហ៊ុន៖ **ហ្វា តើហ្វមមីង សូសល អេនធើប្រាយ**
លេខបញ្ជីពាណិជ្ជកម្ម៖ B១០២-២២០០០៥៨២៦
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ១០០៦៩១៨ ផ
**តំណាងដោយ លោក ហួត តារា ជានាយកក្រុមហ៊ុន**
អាសយដ្ឋាន៖ ភូមិស្វាយដង្គំ សង្កាត់ស្វាយដង្គំ ក្រុង/ខេត្ត សៀមរាប
ទូរស័ព្ទលេខ៖ ០១៦ ៦១៦ ០២២ Email៖ info@pharecircus.org
តទៅហៅ **ហ្វា តើហ្វមមីង សូសល អេនធើប្រាយ រឺ សហគ្រាសដើម្បីសង្គមហ្វារ**

និង

**កញ្ញា. ណាង សក្កា** ថ្ងៃខែឆ្នាំកំណើត ០២. ០៧. ១៩៩២ និងកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៧០៦៩១៤៣ ជាប្រតិភូបុគ្គលិក តំណាងសិល្បករ សិល្បការិនីកម្ពុជា និងបុគ្គលិកនិយោជិតរបស់ក្រុមហ៊ុន **ហ្វា តើហ្វមមីង សូសល អេនធើប្រាយ** ។
តទៅហៅ "**ប្រតិភូបុគ្គលិក**"

ភាគីទាំងពីរ បានព្រមព្រៀងគ្នាដូចតទៅ៖

## ១. មូលហេតុព្យួរកិច្ចសន្យា

សហគ្រាសដើម្បីសង្គមហ្វារត្រូវបានផ្អាកសកម្មភាពអាជីវកម្ម ឈ្មោះ **ហ្វា តើហ្វមមីង សូសល អេនធើប្រាយ** ជាបន្ទាន់ តាមរយៈសេចក្តីណែនាំ លេខ**០០២.២០ស/ណាន** ដោយរដ្ឋបាលខេត្តសៀមរាប ស្តីពីវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២០ គិតចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ រហូតមានសេចក្តីណែនាំបន្ថែម។

## ២. រយៈពេលព្យួរកិច្ចសន្យាការងារ

ភាគីទាំងពីរ បានព្រមព្រៀងគ្នាព្យួរកិច្ចសន្យាការងារ របស់សិល្បករ សិល្បការិនីកម្ពុជា និងបុគ្គលិកនិយោជិតចំនួន១០៩ នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១០៩នាក់ រយៈពេល ០២ ខែ

ដោយគិតចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២០។

**៣. ការឧបត្ថម្ភ**

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ **ហ្វារ ភើហ្វមមីង សូសល អេនធើប្រាយ** បានព្រមព្រៀងផ្តល់ជូនសិល្បករ សិល្បការិនីកម្ពុជា និងបុគ្គលិកនិយោជិត ដូចតទៅ៖

១. កញ្ចប់អត្ថប្រយោជន៍ការធានារ៉ាប់រងឯកជន លើសុខភាពនិងគ្រោះថ្នាក់ មានប្រសិទ្ធភាពរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

២. ការសម្រាកមានបៀវត្ស គិតចាប់ពីថ្ងៃទី១៨ ខែមីនាឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។

**៤. សេចក្តីបញ្ជាក់របស់គូភាគី**

ក្នុងកិច្ចព្រមព្រៀងនេះ ភាគីទាំងពីរបានចុះហត្ថលេខា ដោយពុំមានការបង្ខិតបង្ខំឡើយ។

រាល់លក្ខខណ្ឌ និងប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានពន្យល់បកស្រាយយ៉ាងលម្អិត និងបានពេញលេញដោយភាគីទាំងពីរ។

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
សៀមរាប, ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២០

**ហ្វារ ភើហ្វមមីង សូសល អេនធើប្រាយ**

ក្រុមហ៊ុន ហ្វារ ភើហ្វមមីង សូសល អេនធើប្រាយ
PHARE PERFORMING SOCIAL ENTERPRISE Co Ltd
KINGDOM OF CAMBODIA

ឈ្មោះ៖ **លោក. ហួត តារា**

**"ប្រតិភូបុគ្គលិក"**

ឈ្មោះ៖ **កញ្ញា. ណាង សក្តា**